# ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា

## ជំពូក ១១

## បរិក្ខារការពារខ្លួន (PPE)

អគ្គលេខាធិការដ្ឋាន
អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
អគារថ្មីផ្លូវលេខ ២៧៣ កែង ៥១៦ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ
ទូរស័ព្ទលេខ: ០២៣-៨៨៥-៩៤១ | ០២៣-៨៨១-៤៩២
គេហទំព័រ: www.cmaa.gov.kh

# មាតិកា


មាតិកា ........ ២
សេចក្តីផ្តើម ........ ៣
សុវត្ថិភាព និង សុខុមាលភាពវិជ្ជាជីវៈ-បរិក្ខារការពារខ្លួន ........ ៤
១.ទ្រង់ទ្រាយ ........ ៤
២.តម្រូវការនៃបរិក្ខារការពារខ្លួន ........ ៤
២.១.ទូទៅ ........ ៤
២.២.ការការពារពីមីនខ្យល់ ........ ៤
២.៣.ការការពារពីមីនជះអំបែង ........ ៥
២.៤. ការដ្ឋានកំទេចគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ........ ៦
៣.ការទទួលខុសត្រូវ ........ ៦
៣.១. តម្រូវការទូទៅ ........ ៦
៣.២. ការទទួលខុសត្រូវកំរិតជាតិ ........ ៦
៣.៣. ការទទួលខុសត្រូវរបស់និយោជក ........ ៦
៣.៤. ការទទួលខុសត្រូវរបស់និយោជិក ........ ៧

## សេចក្តីផ្តើម

ការកាត់បន្ថយគ្រោះថ្នាក់តាមដែលអាចធ្វើបានដល់គ្រប់បុគ្គលិកប្រតិបត្តិការនៅតាមការដ្ឋានដោះមីនការដ្ឋានកំទេចគ្រឿងផ្ទុះ និងការផ្តល់សុវត្ថិភាពលើបរិយាកាសការងារ គឺជាមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងសកម្មភាពកំចាត់មីន (សូមអានស្តង់ដាជំពូក០៩)។ ការកាត់បន្ថយគ្រោះថ្នាក់ វាពាក់ព័ន្ធទៅនឹងការបញ្ចូលគ្នានៃសុវត្ថិភាពការងារជាក់ស្តែង និងសុវត្ថិភាពនៃនីតិវិធីប្រតិបត្តិការ ការត្រួតពិនិត្យ ការគ្រប់គ្រងគុណភាព ការអប់រំសមស្របនិងការបណ្តុះបណ្តាល ការរៀបចំសំភារៈការពារសុវត្ថិភាព និងបញ្ញត្តិទាំងឡាយនៃការប្រើប្រាស់បរិក្ខារការពារខ្លួនប្រកបដោយប្រសិទ្ធភាព។

នៅក្នុងកំរិតអប្បរិមាមួយ អ្នកដោះមីន ឬគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះទាំងអស់នៅកម្ពុជា ត្រូវទទួលបាននូវសំលៀកបំពាក់ ស្បែកជើងដែលងាយស្រួលធ្វើការងារ ស្របទៅនឹងភារកិច្ច និងលក្ខខ័ណ្ឌភូមិសាស្រ្តនៅក្នុងមូលដ្ឋាន។

ត្រូវចាត់ទុកបរិក្ខារការពារខ្លួន "ជាមធ្យោបាយចុងក្រោយបំផុត" សំរាប់ការពារប្រឆាំងនឹងអានុភាពនៃគ្រោះថ្នាក់មីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។ ត្រូវចាត់ទុកថានេះជាវិធានការការពារចុងក្រោយដែលត្រូវយកមកអនុវត្ត បន្ទាប់ពីការរៀបចំផែនការគ្រប់យ៉ាង ការបណ្តុះបណ្តាល និងការខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយគ្រោះថ្នាក់។ ទី១"បរិក្ខារការពារខ្លួន" ការពារបានតែអ្នកដែលពាក់វាប៉ុណ្ណោះ រីឯវិធានការនៃការត្រួតពិនិត្យគ្រោះថ្នាក់ខាងដើម អាចការពារមនុស្សគ្រប់ៗគ្នានៅកន្លែងប្រតិបត្តិការ។ ទី២"តាមទ្រឹស្តី" កំរិតអតិបរិមានៃការការពារ ពុំសូវបានទទួលផលពីបរិក្ខារការពារខ្លួននោះឡើយ នៅក្នុងការអនុវត្តន៍ជាក់ស្តែង មានការលំបាកក្នុងការវាយតំលៃលើកំរិតពិតប្រាកដនៃការការពារប្រកបដោយប្រសិទ្ធភាព គឺអាចទទួលបានពីបរិក្ខារការពារខ្លួនដែលមានលក្ខណៈសមរម្យប៉ុណ្ណោះ ដោយត្រូវពាក់ឲ្យបានត្រឹមត្រូវ និងមានការថែទាំ និងប្រើប្រាស់ត្រឹមត្រូវ។ ទី៣"បរិក្ខារការពារខ្លួន" នឹងដាក់បន្ទុកដល់អ្នកពាក់បន្ថែមនូវការកំណត់ការធ្វើចលនា ការមើល ឬតម្រូវឲ្យមានការស្ពាយទំងន់បន្ថែមទៀត។

គ្រោះថ្នាក់ចំពោះអ្នកដោះមីន ច្រើនតែបណ្តាលមកពីមីនខ្យល់ប្រឆាំងមនុស្ស មីនជះអំបែងប្រឆាំងមនុស្ស មីនប្រឆាំងរថក្រោះ និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។ មីនខ្យល់ប្រឆាំងមនុស្ស គឺជាមីនដែលបានជួបប្រទះច្រើនបំផុត នៅក្នុងសកម្មភាពកំចាត់មីន ហើយបានបង្កអោយមានជនរងគ្រោះយ៉ាងច្រើនសន្ធឹកសន្ធាប់។ នៅក្នុងចំងាយជិតបំផុត កំរិតអំណាចនៃការជះអំបែងរបស់មីនប្រឆាំងមនុស្ស និងមីនប្រឆាំងរថក្រោះ ធ្វើឲ្យបរិក្ខារការពារខ្លួន មិនអាចទប់ទល់បានឡើយ។ ដូច្នេះ មីនបែបនេះមានឥទ្ធិពល និងអានុភាពអាចបង្កអោយមាន "ជនរងគ្រោះទី២" ទៀត។ ជាទូទៅពេលដែលគេប្រទះឃើញ គ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅពេលប្រតិបត្តិការ គ្រាប់ទាំងនោះច្រើនតែគាំងមិនដំណើរការ (លើកលែងគ្រាប់តូចៗដែលចេញពីគ្រាប់ធំៗ)។ តាមធម្មតាគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ផ្ទុកទៅដោយលោហធាតុច្រើនដែលក្នុងករណីភាគច្រើនវាស្ថិតនៅលើដី ឬកប់ក្រោមដីរាក់ៗ ហើយករណីខ្លះទៀតអាចបង្កគ្រោះថ្នាក់តិចជាងមីន។
ប្រភេទនៃគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះផ្សេងៗគ្នា
មានន័យថាការការពារកុំឲ្យមានគ្រោះថ្នាក់ច្រើនត្រូវបានដោះស្រាយតាមនីតិវិធីប្រសើរជាងពឹងផ្អែកលើបរិក្ខារការពារដែលផលិតឡើងសំរាប់ការពារជាបឋមនៃកិច្ចប្រតិបត្តិការបោសសំអាតមីនផ្នែកមនុស្សធម៌។

# សុវត្ថិភាព សុខុមាលភាពវិជ្ជាជីវៈ
# បរិក្ខារការពារខ្លួន

## ១.ទំនាក់ទំនង

ស្តង់ដានេះផ្តល់សេចក្តីបញ្ជាក់ និងការណែនាំដល់ប្រតិបត្តិករដោះមីន ពីតម្រូវការជាអប្បបរិមានៃបរិក្ខារការពារខ្លួនរួមទាំងអាវការពារសំរាប់ប្រើនៅពេលបោសសំអាតមីននៅកម្ពុជា។

ស្តង់ដានេះ មិនបានផ្តល់ការណែនាំពីលក្ខណៈសម្បត្តិនៃការផលិតសំលៀកបំពាក់ការពារ ឬការសាកល្បង និងនីតិវិធីនៃការវាយតំលៃឡើយ។

## ២.តម្រូវការនានានៃបរិក្ខារការពារខ្លួន

### ២-១- ជាទូទៅ

កំរិតនៃបរិក្ខារការពារខ្លួនដែលផ្តល់អោយសំរាប់ប្រើប្រាស់ក្នុងតំបន់គ្រោះថ្នាក់ ត្រូវផ្អែកលើកត្តាមួយចំនួនរួមមានសភាពនៃគ្រោះថ្នាក់ក្នុងមូលដ្ឋាន នីតិវិធីប្រតិបត្តិការ ការអនុវត្តន៍ និងលក្ខខ័ណ្ឌជុំវិញក្នុងមូលដ្ឋាន។

ត្រូវបង្ហាត់បង្រៀនពីការប្រើប្រាស់ ការថែរក្សា និងការរៀបចំទុកដាក់បរិក្ខារការពារខ្លួនអោយបានត្រឹមត្រូវក្នុងការប្រើប្រាស់ក្នុងប្រតិបត្តិការដោះមីនរបស់ខ្លួន។ ត្រូវផ្តល់មធ្យោបាយសំរាប់ការរក្សាទុក និងការលើកដាក់អោយបានសមស្រប។ ត្រូវត្រួតពិនិត្យបរិក្ខារការពារជាប្រចាំ ដើម្បីធានាបាននូវការប្រើប្រាស់សមស្រប។

គ្រប់អ្នកដោះមីនទាំងអស់ដែលកំពុងធ្វើការបោសសំអាតមីន និងភ្ញៀវដែលមកទស្សនកិច្ចការដ្ឋានក្នុងពេលប្រតិបត្តិការដោះមីន ត្រូវពាក់បរិក្ខារការពារខ្លួនឲ្យបានត្រឹមត្រូវជាដាច់ខាត។

### ២-២- ការការពារមីនខ្យល់

បរិក្ខារការពារខ្លួន គួរមានសមត្ថភាពគ្រប់គ្រាន់ក្នុងការការពារទប់ទល់នឹងប្រសិទ្ធភាពនៃការផ្ទុះម្សៅ តេ អិន តេ ទំងន់២៤០ក្រាម ពីគំលាតជើងដោយត្រូវប្រើវាដោយអនុលោមទៅតាមបទដ្ឋានប្រតិបត្តិការ។ ឧបករណ៍សំរាប់កាត់បន្ថយគ្រោះថ្នាក់នេះ ត្រូវរាប់បញ្ចូលនូវចំណុចជាអប្បរិមាដូចខាងក្រោម:

ក. ការការពារផ្នែកខាងមុខទៅតាមសកម្មភាពតម្រូវ ដែលមានសមត្ថភាពការពារទល់នឹងប្រសិទ្ធភាពនៃការផ្ទុះម្សៅ តេ អិន តេ ទំងន់២៤០ក្រាម ក្នុងចំងាយ៣០សម ពីដងខ្លួន។

ខ. ការការពារភ្នែក ដែលមានសមត្ថភាពទប់ទល់ប្រឆាំងនឹងប្រសិទ្ធភាពនៃការផ្ទុះម្សៅ តេ អិន តេ ទំងន់២៤០ក្រាម ក្នុងចំងាយ៦០សម។ ការការពារផ្ទៃមុខ ត្រូវផ្តល់ការការពារទាំងស្រុងលើផ្ទៃមុខ និងបំពង់ក ដោយដាក់ភ្ជាប់ទៅនឹងឧបករណ៍ការពារពិសេសផ្សេងទៀត។

ឧបករណ៍ការពារផ្នែកខាងមុខដែលបានផ្តល់អោយនិយោជិក ទោះជាតម្រូវអោយលត់ជង្គង់ អង្គុយ ក្រាប ក៏ដោយ ត្រូវរៀបចំឡើងដើម្បីការពារភ្នែក បំពង់ក (កផ្នែកខាងមុខ) ដើមទ្រូង ពោះ និងអង្គជាតិ។

ឧបករណ៍ប្រើដោយដៃទាំងអស់ ត្រូវផលិតឡើងដោយការពារមិនអោយក្លាយជាអំបែងដល់កំរិតទាបបំផុត នៅពេលដែលមានឧប្បទ្ទវហេតុផ្ទុះមីន។ ឧបករណ៍ទាំងនោះអាចត្រូវប្រើដោយមានឧបករណ៍ការពារដៃ ដូចជាខែលការពារដៃ និងស្រោមដៃ។ ឧបករណ៍នេះគួរធ្វើឡើងសំរាប់ប្រើលើផ្ទៃដែលមានមុំតូច និងផ្តល់គម្លាតអោយបានគ្រប់គ្រាន់ពីចំណុចនៃបន្ទុះ។

នៅក្នុងដំណើរការកាត់បន្ថយគ្រោះថ្នាក់ ប្រតិបត្តិករដោះមីនអាចគិតគូរផ្តល់ស្បែកជើងសំរាប់ការពារការជះនៃខ្យល់ពីមីនសំរាប់ការពារជើង និងអវៈយវៈខាងក្រោម បើកំរិតគ្រោះថ្នាក់ធំពេក ហើយការអនុវត្តន៍បទដ្ឋានប្រតិបត្តិការមិនអាចកាត់បន្ថយបានទេនោះ ត្រូវផ្តល់ស្បែកជើងការពារមីនខ្យល់ដែលបានពិសោធន៍ និងបង្ហាញថាស្បែកជើងនោះមានប្រសិទ្ធភាពក្នុងការកាត់បន្ថយគ្រោះថ្នាក់ប្រភេទនោះបាន។

លើសពីនេះ ប្រតិបត្តិករដោះមីន អាចគិតគូរផ្តល់ទ្រនាប់កែងដៃ ទ្រនាប់ជង្គង់ ដែលអាចឲ្យអ្នកដោះមីនមានភាពងាយស្រួលក្នុងការបំពេញការងារខ្លួន។

**២-៣- ការការពារមីនជះអំបែង**

បរិក្ខារការពារខ្លួនបច្ចុប្បន្ន មិនអាចទប់នឹងប្រភេទមីនជះអំបែងបានឡើយ ប៉ុន្តែអ្នកឯកទេសខាងកំទេចគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ បានបញ្ជាក់ថាភាពចាំបាច់ដំបូងគឺត្រូវកាត់បន្ថយគ្រោះថ្នាក់តាមនីតិវិធីនៃបទដ្ឋានប្រតិបត្តិការ។ ទោះជាយ៉ាងនេះក្តី វាក៏អាចផ្តល់ការការពារប្រឆាំងនឹងមីនខ្យល់ផ្សេងៗ និងការពារកុំអោយមានជនរងគ្រោះទី២ទៀត ទោះជាការគំរាមគំហែងនេះ មិនអាចបំបាត់ចោលតាមនីតិវិធីក៏ដោយ។ បរិក្ខារការពារខ្លួនបានផ្តល់អោយ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ជាអាប្បរិមាដូចខាងក្រោម:

ក. អាវក្រោះការពារអំបែងដែលមានការទទួលស្គាល់ដោយអន្តរជាតិ ដែលអាចការពារកំរិត V៥០ ល្បឿន ៤៥០ម/ក្នុងមួយវិនាទី សំរាប់អំបែងទំងន់១.១០២g (ស្តង់ដានេះនឹងបន្តប្រើប្រាស់រហូតមានជំរើសថ្មីទៅតាមស្តង់ដាអន្តរជាតិត្រូវបានរៀបចំមកជំនួស)។

ខ. របាំងការពារមុខដូចបានរៀបរាប់ក្នុងប្រយោគ២.២(ខ) ខាងលើ។ ទោះជាយ៉ាងណាក្តី តាមការវិភាគលើការប្រើប្រាស់លក្ខណៈវិនិច្ឆ័យចែងក្នុងគោលការណ៍ណែនាំ និងស្តង់ដាជំពូក០៩ បង្ហាញអោយឃើញថា របាំងការពារមុខមិនអាចការពារបានគ្រប់គ្រាន់ឡើយ ដូច្នេះត្រូវពាក់មួកសុវត្ថិភាពបន្ថែមទៀត។ មួកសុវត្ថិភាពគួរមានកំរិតការពារស្រដៀងនឹងអាវក្រោះការពារអំបែង ដែលជ្រើសរើសដោយប្រតិបត្តិករដោះមីន។

**ចំណាំ១**:ឧបករណ៍ការពារភ្នែក គួរមានកំរាស់មិនតិចជាង៥មម។ គួរផ្តល់នូវការការពារផ្នែកខាងមុខទាំងស្រុងមាន មុខ និងបំពង់ក ដោយភ្ជាប់ទៅនឹងឧបករណ៍ការពារខាងមុខពិសេសៗផ្សេងទៀត។ (ដូច្នេះបើអាវក្រោះការពារដងខ្លួន បាំងពីលើក្បាំងការពារមួយជាន់ទៀត នោះក្បាំងមុខនោះអាចស្ថិតនៅពីក្រោយនឹងការបាំងរបស់អាវនោះបាន នៅពេលប្រើប្រាស់)។

### ២-៤- ការរង្វានកំទេចគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

នៅពេលចុះធ្វើការបោសសំអាតគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ឬគ្រាប់យុទ្ធភ័ណ្ឌដែលមានគ្រោះថ្នាក់ផ្សេងៗទៀត ចាំបាច់ត្រូវបង្កើនកំរិតការពារ។ ចំណុចនេះ ត្រូវកំណត់ក្នុងបទដ្ឋានប្រតិបត្តិការ និងដាក់បញ្ចូលទាំងអាវក្រោះការពារខ្លួន ឬក៏ឧករណ៍ពិសេសនានានៃបរិក្ខារការពារខ្លួន។

## ៣.ភារកិច្ចទទួលខុសត្រូវ

### ៣-១- តម្រូវការទូទៅ

អាជ្ញាធរមីន និងប្រតិបត្តិករដោះមីនទាំងអស់ (រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងក្រុមហ៊ុនពាណិជ្ជកម្ម ដែលត្រូវបានទទួលស្គាល់ផ្សេងៗ) ត្រូវប្រើបរិក្ខារការពារខ្លួនដែលជាតម្រូវការកំរិតអាប្បរិមា សំរាប់ប្រើប្រាស់នៅក្នុងសកម្មភាពកំចាត់មីននៅកម្ពុជា។ កាតព្វកិច្ច និងការទទួលខុសត្រូវនៅកំរិតជាតិ និងការទទួលខុសត្រូវរបស់និយោជក និងនិយោជិកមានចែងដូចខាងក្រោម:

### ៣-២- ការទទួលខុសត្រូវលំដាប់ជាតិ

**អាជ្ញាធរមីនត្រូវ:**

ក. រក្សាស្តង់ដាជាតិ

ខ. ត្រួតពិនិត្យការអនុវត្តន៍ស្តង់ដានេះ

គ. កំណត់ពេលពិនិត្យឡើងវិញចំពោះស្តង់ដាជាតិសំរាប់បរិក្ខារការពារខ្លួន ពិនិត្យសើរើការរៀបចំកែប្រែស្តង់ដាអន្តរជាតិ និងបច្ចេកវិជ្ជាសមស្រប ដើម្បីកាត់បន្ថយគ្រោះថ្នាក់។

### ៣-៣- ការទទួលខុសត្រូវរបស់ប្រតិបត្តិករដោះមីន

**ប្រតិបត្តិករដោះមីនត្រូវ:**

ក. អនុវត្តតាមស្តង់ដានេះ និងរាល់ការកែប្រែស្តង់ដាជាតិលើបរិក្ខារការពារខ្លួន

ខ. អនុវត្តតាមតម្រូវការកំណត់ ឬលើសពីការកំណត់សំរាប់ការប្រើបរិក្ខាការពារខ្លួន។ ក្នុងន័យនេះ ត្រូវផ្តល់បរិក្ខារការពារខ្លួនដល់និយោជិកទាំងអស់ ដែលនៅប្រើការបានអាចទប់ទល់នឹងគ្រោះថ្នាក់ និងឆ្លើយតបនឹងតម្រូវការនានានៃនីតិវិធីប្រតិបត្តិការ និងលក្ខខ័ណ្ឌបរិស្ថានផ្សេងទៀត។

គ. ផ្តល់ការបណ្តុះបណ្តាល និងត្រួតពិនិត្យក្នុងការប្រើប្រាស់អោយបានត្រឹមត្រូវ និងការថែរក្សាបរិក្ខារការពារខ្លួន

ឃ. បង្កើត ថែរក្សាបទដ្ឋានប្រតិបត្តិការ ដែលបញ្ជាក់ពីតម្រូវការនានានៃការថែទាំ

ង. ផ្តល់មធ្យោបាយសមស្របសំរាប់ទុកដាក់ ថែទាំ និងដឹកជញ្ជូនបរិក្ខារការពារខ្លួន

ច. បង្កើត និងថែរក្សាការកំណត់ពេលពិនិត្យឡើងវិញ និង អធិការកិច្ចលើបរិក្ខារការពារខ្លួន។

### ៣-៤- កាតព្វកិច្ចរបស់និយោជិក

**និយោជិកទាំងអស់នៃប្រតិបត្តិករដោះមីនត្រូវ:**

ក. ប្រើប្រាស់បរិក្ខារការពារខ្លួនស្របទៅតាមតម្រូវការដែលបានបញ្ជាក់ដោយនិយោជករបស់ខ្លួន និងសេចក្តីបញ្ជាក់របស់ផលិតករ រួមទាំងការប្រើប្រាស់មធ្យោបាយនានាសំរាប់ទុកដាក់ និងដឹកជញ្ជូន។

ខ. ថែទាំបរិក្ខារការពារខ្លួនស្របនឹងបទដ្ឋានប្រតិបត្តិការរបស់ប្រតិបត្តិករដោះមីន និង/ឬសេចក្តីបញ្ជាក់របស់ផលិតករ ឬ គោលការណ៍ណែនាំផ្សេងទៀត។

គ. រាយការណ៍ជូននិយោជកអំពីសំភារៈដែលមានបញ្ហា ឬសំណើសុំកែតម្រូវបទដ្ឋានប្រតិបត្តិការអោយរឹតតែប្រសើរឡើង ដែលអាចកាត់បន្ថយតម្រូវការនៃបរិក្ខារការពារខ្លួនបាន ឬស្នើសុំកែប្រែបរិក្ខារការពារខ្លួនឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។

ភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

សម សុត្ថា